**រដ្ឋបាលព្រៃឈើ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចប្រជុំប្រចាំឆ្នាំលើកទី៦ ឆ្នាំ២០១៩
# គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើជាតិ

## ១. សេចក្តីផ្តើម

សហគមន៍ព្រៃឈើនៅកម្ពុជាបានរៀបចំបង្កើតតាំងពីឆ្នាំ១៩៩៤ តាមរយៈគម្រោងសាកល្បងដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា អង្គការដៃគូជាតិអន្តរជាតិ និងមានការចូលរួមពីសហគមន៍មូលដ្ឋានដែលរស់នៅពឹងអាស្រ័យលើធនធានព្រៃឈើ។ សហគមន៍ព្រៃឈើមានសក្តានុពលក្នុងការអភិរក្សធនធានព្រៃឈើធ្វើឲ្យប្រសើរឡើងនូវផលិតភាពរបស់ព្រៃនិងដើម្បីគាំទ្រដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ព្រមទាំងរក្សាបាននូវលំនឹងប្រព័ន្ធអេកូឡូស៊ី និងចូលរួមកាត់បន្ថយនូវការប្រែប្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំបង្កើតនូវក្របខណ្ឌគោលនយោបាយ និងច្បាប់សម្រាប់គាំទ្រដល់ការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ក្នុងនោះរួមមាន គោលនយោបាយវិស័យព្រៃឈើជាតិឆ្នាំ២០០២ ច្បាប់ស្តីពីព្រៃឈើត្រូវបានរដ្ឋសភាអនុម័តនិងបានប្រកាសឲ្យប្រើតាំងពីឆ្នាំ២០០២ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើឆ្នាំ២០០៣ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើឆ្នាំ២០០៦ និងកម្មវិធីព្រៃឈើជាតិអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅចុងឆ្នាំ២០១០ ដែលក្នុងនោះកម្មវិធីទី៤គឺជាកម្មវិធីសហគមន៍ព្រៃឈើ។

អនុវត្តតាមគោលនយោបាយនិងលិខិតបទដ្ឋានច្បាប់ ព្រមទាំងមានការចូលរួមគាំទ្រភាគីពាក់ព័ន្ធ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ នៅប្រទេសកម្ពុជាបានបង្កើតសហគមន៍ព្រៃឈើសរុបចំនួន **៦៣៦កន្លែង** គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ៥១៦ ៨១៧ហិកតា ស្ថិតនៅក្នុង ២១ខេត្ត ៩៩ស្រុក ៣១២ឃុំ ៩៥៤ភូមិ និងមានការចូលរួមពីសហគមន៍នៅមូលដ្ឋានចំនួន ១៦៩ ២៤៨គ្រួសារ ក្នុងនោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍សរុបចំនួន**៥៩៤សហគមន៍** គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ៤៤៣ ៣២៩ហិកតា រដ្ឋបាលព្រៃឈើបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍រវាងខណ្ឌរដ្ឋបាលព្រៃឈើសាមីនិងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើសរុបចំនួន**៤៤៩សហគមន៍** គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ៣៦៨ ២៨៣ហិកតា និងរដ្ឋបាលព្រៃឈើបានឯកភាពលើផែនការគ្រប់គ្រងព្រៃសហគមន៍សរុបចំនួន **៩៤សហគមន៍** គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ៦៣ ៦៣៩ហិកតា។

កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០មានចំនួន៦កម្មវិធី ហើយកម្មវិធីសហគមន៍ព្រៃឈើគឺជាកម្មវិធីទី៤ដែលបានកំណត់នូវសកម្មភាពចំបងចំនួន៣គឺ ការបង្កើតសហគមន៍ព្រៃឈើ ការពង្រឹងស្ថាប័ន និងការផ្តល់សេវាកម្ម ក្នុងនោះការពង្រឹងគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ជាតិ (គសកស.ជ) គឺជាផ្នែកមួយនៃការពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលព្រៃឈើនិងអ្នកពាក់ព័ន្ធ។ គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ជាតិត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០៧ ក្នុងគោលបំណងដើម្បីចែករំលែកនូវព័ត៌មាន គាំទ្រដល់ភាគីពាក់ព័ន្ធរៀបចំនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍សហគមន៍ព្រៃឈើនៅកម្ពុជាស្វែងឲ្យមានប្រសិទ្ធភាព។ គសកស.ជ ក៏បានសម្របសម្រួលបង្កើតនូវគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ខេត្ត (គសកស.ខ) ផងដែរ ដើម្បីបង្កើនកិច្ចសហការជាមួយអង្គការជាដៃគូនៅថ្នាក់ក្រោមជាតិ ជាពិសេសផ្លាស់ប្តូរបទពិសោធន៍ ពង្រឹងអភិបាលកិច្ច ដោះស្រាយនូវបញ្ហាដែលកើតមាននៅក្នុងសហគមន៍ព្រៃឈើ។

## ២. គោលបំណង

កិច្ចប្រជុំប្រចាំឆ្នាំលើកទី៦ របស់គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ជាតិ មានគោលបំណងដើម្បីចែករម្លែកនូវការអនុវត្តការងារអភិវឌ្ឍសហគមន៍ព្រៃឈើ និងរៀបចំនូវផែនការយុទ្ធសាស្ត្រ៖

- បង្ហាញអំពីវឌ្ឍនភាព ភាពប្រឈម និងផែនការក្នុងការអនុវត្តការងារសហគមន៍ព្រៃឈើ
- កសាងទំនាក់ទំនងភាគីពាក់ព័ន្ធក្នុងការអនុវត្តការងារសហគមន៍ព្រៃឈើ
- ចែករម្លែកនូវការអនុវត្តការងារអភិវឌ្ឍសហគមន៍ព្រៃឈើតាមរយៈវិធីសាស្ត្រថ្មៃប្រឌិតនានាដែលគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ។

## ៣. វិធីសាស្ត្រ

- បទបង្ហាញ និងពិភាក្សា។

## ៤. ពេលវេលា និងទីកន្លែង

- ថ្ងៃទី០៥-០៦ ខែធ្នូ ឆ្នាំ២០១៩
- នៅសណ្ឋាគារ **អង្គរមីរ៉ាខល** ខេត្តសៀមរាប។

## ៥. អ្នកចូលរួម

កិច្ចប្រជុំនេះ នឹងមានអ្នកចូលរួមមកពីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ខណ្ឌរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន អង្គការដៃគូរអភិវឌ្ឍន៍ បណ្តាញសហគមន៍ព្រៃឈើ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើសរុបចំនួន ១៥០ នាក់ រួមមាន ៖

| | | |
|---|---|---|
| ១ | រដ្ឋបាលព្រៃឈើកណ្តាល | ១០ នាក់ |
| ២ | រដ្ឋបាលព្រៃឈើមូលដ្ឋាន | ២១ នាក់ |
| ៣ | សហគមន៍ព្រៃឈើ | ៨៤ នាក់ |
| ៥ | អង្គការដៃគូ | ៣៥ នាក់ |

## ៦. អ្នករៀបចំកិច្ចប្រជុំ

កិច្ចប្រជុំនេះនឹងសហការរៀបចំដោយរដ្ឋបាលព្រៃឈើ និងដៃគូអភិវឌ្ឍន៍រួមមាន AWG-SF, SDC, EU, RECOFTC, NGO Forum, NTFP-EP, UNDP/Small Grant, FAO, Mlup Baitong, DPA, Caritas, WWF, MJP, IUCN, Forum Syd,។

ក្រុមការងារសម្របសម្រួលកិច្ចប្រជុំរួមមាន៖

1. លោក ឡុង រត្តនៈកុមារ អនុប្រធាន នពស. ទូរស័ព្ទលេខ ០៧៧-៦៨ ០៨ ៣០
2. អ្នកស្រី អ៊ឹម ម៉ារីឌី ប្រធាន កសព. ទូរស័ព្ទលេខ ០១២-៩១ ៥៦ ៨៧
3. លោក តូង សុគន្ធា អនុប្រធាន កសព. ទូរស័ព្ទលេខ ០៩៧-៣៥ ៥៥ ៥៤៦
4. កញ្ញា អ៊ឹម ណារ៉ុង អនុប្រធាន កសព. ទូរស័ព្ទលេខ ០១២-៣៤ ៩៩ ៨៧
5. កញ្ញា មាស ចិន្តា មន្ត្រី កសព. ទូរស័ព្ទលេខ ០១៧-២៩ ៤៥ ១៩
6. លោក ឡាយ គឹមលក្ខ មន្ត្រី កសព.

## ៧. របៀបវារៈ

### កិច្ចប្រជុំប្រចាំឆ្នាំលើកទី៦ របស់គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ជាតិ
### សណ្ឋាគារ **អង្គរមីរ៉ាខល** ខេត្តសៀមរាប ថ្ងៃទី០៥-០៦ ខែធ្នូ ឆ្នាំ២០១៩

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| *ថ្ងៃទី១* | *០៥ ធ្នូ ២០១៩* | |
| ម៉ោង ០៨:០០ | ចុះឈ្មោះសិក្ខាកាម | - កញ្ញា អ៊ឹម ណារ៉ុង<br>- កញ្ញា មាស ចិន្ដា |
| ម៉ោង ០៨:៣០ | **ពិធីបើកកិច្ចប្រជុំ៖**<br>- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- របាយការណ៍វឌ្ឍនភាពរបស់ គសកស.ជ ដោយលោក **ឡុង រត្តនៈកុមារ** អនុប្រធាននាយកដ្ឋានព្រៃឈើនិងសហគមន៍ព្រៃឈើ<br>- មតិចាប់អារម្មណ៍របស់លោកស្រី **ហ៊ូ កល្យាណ** នាយកអង្គការ RECOFTC ប្រចាំកម្ពុជា<br>- សុន្ទរកថាបើកកិច្ចប្រជុំ របស់ឯកឧត្ដម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ថតរូបរួមគ្នាជាអនុស្សាវរីយ៍ | - អ្នកស្រី អ៊ឹម ម៉ារីឌី |
| ម៉ោង ០៩:៣០ | សម្រាកអាហារសម្រន់ | |
| ម៉ោង ១០:០០ | <u>**ប្រធានបទទី១៖ យន្តការសម្របសម្រួលគ្រប់គ្រងសហគមន៍ព្រៃឈើ**</u><br>1. បទពិសោធន៍នៃការចុះបញ្ជិកាព្រៃសហគមន៍នៅខេត្តពោធិ៍សាត់ ដោយលោក **ពារម្យ មនោ** នាយសង្កាត់រដ្ឋបាលព្រៃឈើលាច<br>2. ដំណើរការចុះបញ្ជិកាព្រៃសហគមន៍នៅខេត្តស្ទឹងត្រែង ដោយលោក **អន ចន្ទសុជាតិ** នាយខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង<br>3. យន្តការសម្របសម្រួលសហគមន៍ព្រៃឈើជាមួយអ្នកពាក់ព័ន្ធ ដោយលោក **ម៉ុន សុធី** នាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ<br>4. បណ្តាញសហគមន៍ព្រៃឈើខេត្តកំពង់ធំ ដោយលោកស្រី **កែវ វណ្ណា** ប្រធានបណ្ដាញសហគមន៍ | អ្នកសម្របសម្រួល<br>លោក ឡុង រត្តនៈកុមារ<br>និងអ្នកស្រី អ៊ឹម ម៉ារីឌី<br><br>(រយៈពេល២០នាទី ក្នុងបទបង្ហាញនីមួយៗ) |
| ម៉ោង ១២:០០ | សម្រាកអាហារថ្ងៃត្រង់ (រៀបចំជូន) | |
| ម៉ោង ១៣:៣០ | <u>**ប្រធានបទទី២៖ ការគ្រប់គ្រង និងអភិវឌ្ឍព្រៃសហគមន៍**</u><br>1. ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ដោយលោក **តូច សុគន្ធា** អនុប្រធានការិយាល័យសហគមន៍ព្រៃឈើ<br>2. បទពិសោធន៍នៃការអភិវឌ្ឍព្រៃសហគមន៍ ដោយលោក **ឃួន ម៉ុន** ប្រធានសហគមន៍ព្រៃឈើព្រៃក្បាលបី ខេត្តកំពង់ធំ<br>3. បទពិសោធន៍ក្នុងការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍បូរីអូរស្វាយ ខេត្តស្ទឹងត្រែង ដោយលោក **គង់ ឧត្តី** ប្រធានសហគមន៍ព្រៃឈើ<br>4. ឥណទានសហគមន៍ព្រៃឈើគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍អូរគ្រៀង ដោយលោកស្រី **ស៊ី គឹមសៀវ** ប្រធានក្រុមឥណទានសហគមន៍ព្រៃឈើ ខេត្តក្រចេះ | អ្នកសម្របសម្រួល<br>លោកស្រី ហ៊ូ កល្យាណ<br>និងលោក ហេង ដា<br><br>(រយៈពេល២០នាទី ក្នុងបទបង្ហាញនីមួយៗ) |
| ម៉ោង ១៥:៣០ | សម្រាកអាហារសម្រន់ | |

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ម៉ោង ១៦:០០ | សំយោគលទ្ធផលថ្ងៃទី១ | លោក សូ ថន |
| ***ថ្ងៃទី២*** | ***០៦ ធ្នូ ២០១៩*** | |
| ម៉ោង ០៨:៣០ | ប្រធានបទទី៣៖ ព្រៃសហគមន៍ និង ការលើកកម្ពស់ជីវភាពរស់នៅ<br>1. ការអនុវត្តកសិរុក្ខកម្មនៅក្នុងព្រៃសហគមន៍ព្រៃខ្មៅ ខេត្តកំពត ដោយលោក **ម៉ែន ណាវ** ប្រធានសហគមន៍ព្រៃឈើព្រៃខ្មៅ<br>2. កសិរុក្ខកម្មនៅក្នុងព្រៃសហគមន៍អូរបាក់ត្រា ខេត្តពោធិ៍សាត់ ដោយលោក ....... ប្រធានសហគមន៍ព្រៃឈើ<br>3. ការគ្រប់គ្រងសហគមន៍ព្រៃឈើ និងទេសចរណ៍ធម្មជាតិ ដោយលោកស្រី **ឈឿន សុឌី** ប្រធានសហគមន៍ព្រៃឈើ | អ្នកសម្របសម្រួល<br>លោក ស៊ឹម ប៊ុនធឿន<br>លោក ធឹង ស៊ុវិរិយ៉ា<br><br>(រយៈពេល២០នាទីក្នុងបទបង្ហាញនីមួយៗ) |
| ម៉ោង ១០:០០ | សម្រាកអាហារសម្រន់ | |
| ម៉ោង ១០:៣០ | 4. ការអភិវឌ្ឍសហគ្រាសសហគមន៍កែច្នៃទ្រាំង ដោយលោក **សាត ទីវ៉ៃ** បុគ្គលិកអង្គការ NTFP-EP<br>5. ការអភិវឌ្ឍសហគ្រាសសហគមន៍ការប្រមូលឃ្មុំព្រៃ ដោយលោក **ឯក សុវណ្ណា** សហគមន៍ព្រៃឈើប្រាសាទទឹកខ្មៅ ខេត្តក្រចេះ<br>6. ការបង្កើនជីវភាពសហគមន៍ព្រៃឈើតាមរយៈគម្រោងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈរេដបូក ដោយលោក **ឆុច ផល្លា** អនុប្រធាននាយកដ្ឋានឧស្សាហកម្មព្រៃឈើនិងសហ.អន្តរជាតិ<br>7. ការណែនាំអំពីគម្រោងស្ដារផែនទេសភាពព្រៃឈើ ដោយមន្ត្រីតំណាងអង្គការ FAO | (ត)<br>អ្នកសម្របសម្រួល<br>លោក ស៊ឹម ប៊ុនធឿន<br>លោក ធឹង ស៊ុវិរិយ៉ា |
| ម៉ោង ១១:៣០ | វឌ្ឍនភាព និងផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍសហគមន៍ព្រៃឈើនៅកម្ពុជា ដោយលោក **ឡុង រត្នៈកុមារ** អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ | អ្នកស្រី អ៊ឹម ម៉ារីឌី |
| ម៉ោង ១២:០០ | សម្រាកអាហារថ្ងៃត្រង់ (រៀបចំជូន) | |
| ម៉ោង ១៣:៣០ | ការពិភាក្សារួម ដឹកនាំដោយឯកឧត្តមបណ្ឌិត **កែវ អូម៉ាលីស្ស** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | អ្នកស្រី អ៊ឹម ម៉ារីឌី |
| ម៉ោង ១៥:៣០ | សម្រាកអាហារសម្រន់ | |
| ម៉ោង ១៦:០០ | **<u>ពិធីបិទកិច្ចប្រជុំ</u>៖**<br>- សរុបលទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំលើកទី៦ ដោយលោក **ឡុង រត្នៈកុមារ** អនុប្រធាននាយកដ្ឋានព្រៃឈើនិងសហគមន៍ព្រៃឈើ<br>- សុន្ទរកថាបិទកិច្ចប្រជុំ ដោយឯកឧត្តមបណ្ឌិត **កែវ អូម៉ាលីស្ស** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | អ្នកស្រី អ៊ឹម ម៉ារីឌី |